# ស្ថានភាពអតិផរណានៅខែកុម្ភៈ ឆ្នាំ២០១៦

*******

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែកុម្ភៈ ឆ្នាំ២០១៦ បានកើនឡើង ០,៤% ធៀបនឹងខែកន្លងទៅ ឬ បានកើនឡើង **២,៣%** ធៀបនឹង១២ខែមុន។ បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានការកើនឡើង ជាពិសេសសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានកើនឡើង ៤,៧% ក្នុងនោះថ្លៃត្រីស្រស់កើនឡើង ៨,៨% ថ្លៃសាច់ជ្រូកកើនឡើង ៥,១% ថ្លៃសាច់គោកើនឡើង ១០,៤% ថ្លៃសាច់មាន់កើនឡើង ៤,៨% ថ្លៃបន្លែផ្លែឈើកើនឡើងជាង ៣% សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ បានកើនឡើង ៩,៧% និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន បានកើនឡើង ៦,៦%។

ប៉ុន្តែ ក៏មានសន្ទស្សន៍ថ្លៃទំនិញខ្លះធ្លាក់ចុះដែរ ដូចជា សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បានថយចុះចំនួន ៣,៦% ក្នុងនោះ ថ្លៃឧស្ម័នបានថយចុះ ២៤,១% និងឥន្ធនៈរាវបានថយចុះ ៣,១% សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានថយចុះចំនួន ៦,២% ក្នុងនោះ ថ្លៃប្រេងឥន្ធនៈ និងខ្លាញ់បានថយចុះ ១១,៩% ថ្លៃប្រេងសាំងបានថយចុះ ១២,១% ប្រេងម៉ាស៊ូតបានថយចុះ ១២,៣% និងសេវាកម្មដឹកជញ្ជូន បានថយចុះ ១៨,៨%។

ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង ១២ ក្រុម មានដូចខាងក្រោម÷

| | ធៀបខែមុន | ធៀប ១២ខែមុន |
|---|---|---|
| មុខទំនិញគ្រប់មុខ | ០,៤ | **២,៣** |
| ១-អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | ០,៩ | ៤,៧ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ០,១ | ៩,៧ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -០,១ | ៣,៧ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -០,៤ | -៣,៦ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | ១,៣ | ១,៩ |
| ៦-សុខាភិបាល | ០,១ | ១,៧ |
| ៧-ការដឹកជញ្ជូន | -០,៤ | -៦,២ |
| ៨-គមនាគមន៍ | ០,២ | ១,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | ០,៥ | ៣,០ |
| ១០-ការសិក្សា | ០,០ | ០,៦ |
| ១១-ភោជនីយដ្ឋាន | ០,០ | ៦,៦ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,៥ | -២,៣ |

តាមការសង្កេតសន្ទស្សន៍ថ្លៃទំនិញមាននិន្នាការកើនឡើងនៅដើមឆ្នាំ ២០១៦ នេះ ដោយសារការកើនឡើងថ្លៃត្រី សាច់ និងបន្លែផ្លែឈើ ការកើនឡើងប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់ឈ្នួលកម្មករនិយោជិត ការបន្តរីកលូតលាស់សេដ្ឋកិច្ចជាតិ ការរឹតបន្តឹងការអនុវត្តលើវិស័យពន្ធដារនិងពន្ធគយ និងការកើនឡើងវិញនៃតម្លៃប្រេងលើទីផ្សារអន្តរជាតិ។ តាមការធ្វើចំណោលដោយឈរលើសេណារីយ៉ូកណ្តាល នៅខែធ្នូ ឆ្នាំ២០១៦ អតិផរណាប្រចាំឆ្នាំ (year on year) អាចមានអត្រា ៣,៣% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ២,៩%។

នោះជាយ៉ាងនេះក្តី បើសិនជាគ្មានការរកដំណោះស្រាយដើម្បីកាត់បន្ថយកំណើនថ្លៃ ជាពិសេសថ្លៃម្ហូបអាហារនោះ អតិផរណានៅឆ្នាំ២០១៦ អាចនឹងមានកំរិតខ្ពស់ជាងនេះ។

**តារាង÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារ**
**មួយចំនួនប្រចាំឆ្នាំ២០១៥-២០១៦ (%)**

| មុខទំនិញ | ២០១៥ | | ២០១៦ | |
|---|---|---|---|---|
| | មករា | កុម្ភៈ | មករា | កុម្ភៈ |
| អង្ករ | 0.8 | 1.2 | 2.8 | 2.3 |
| សាច់គោ | 3.4 | 4.4 | 8.7 | 10.4 |
| សាច់មាន់ | 2.0 | 3.2 | 3.2 | 4.8 |
| សាច់ទា | 3.5 | 5.4 | 3.2 | 1.8 |
| សាច់ជ្រូក | 7.4 | 7.8 | 4.0 | 5.1 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 4.8 | 6.6 | 9.8 | 8.4 |
| ក្នុងនោះត្រីស្រស់ | 5.6 | 7.2 | 10.3 | 8.8 |
| ផ្លែឈើ | 4.1 | 7.1 | 5.5 | 3.6 |
| ផ្លែឈើស្រស់ | 5.2 | 8.5 | 6.0 | 3.7 |
| បន្លែ | 5.3 | 7.9 | 2.4 | 3.0 |
| បន្លែជាស្លឹក | 5.2 | 10.8 | -0.7 | -2.0 |
| បន្លែជាផ្លែ | 8.5 | 10.5 | 2.5 | 5.7 |

**ការប្រែប្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ (ថ្លៃមូលដ្ឋានឆ្នាំ ២០០៦)**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

តារាងឧបសម្ព័ន្ធ៣៖ អតិផរណាប្រចាំឆ្នាំ (%)

| ប្រទេស | ២០១៥ | | ២០១៦ | |
|---|---|---|---|---|
| | មករា | កុម្ភៈ | មករា | កុម្ភៈ |
| ប្រទេសកម្ពុជា | 0.4 | 1.6 | 3.0 | 2.3 |
| ប្រទេសវៀតណាម | 0.9 | 0.3 | -36.7 | -33.3 |
| ប្រទេសថៃ | -0.41 | -0.52 | -0.53 | -0.50 |
| ប្រទេសម៉ាឡេស៊ី | 1 | 0.09 | 3.53 | 4.19 |
| ប្រទេសឥណ្ឌូនេស៊ី | 6.96 | 6.29 | 4.14 | 4.42 |
| ប្រទេសភីលីពីន | 2.40 | 2.47 | 1.35 | 0.92 |
| ប្រទេសចិន | -1.66 | -0.59 | 0.99 | 0.89 |
| ប្រទេសកូរ៉េខាងត្បូង | 0.83 | 0.55 | 0.79 | 1.24 |
| ប្រទេសជប៉ុន | 2.38 | 2.18 | -0.10 | 0.29 |

កំណត់សម្គាល់៖ ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

រៀបចំ និង ធ្វើចំណោលដោយ

នាយដ្ឋានស្ថិតិ

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ